សំណុំពត៌មានពិតរបស់កម្មវិធីប្រចាំ ឆ្នាំ ២០១៤

FUN TO CATCH TOXIC TO EAT

THE ONLY DUWAMISH SEAFOOD SAFE TO EAT IS SALMON
Loại hải sản an toàn nhất để ăn từ sông Duwamish là cá hồi
El único pescado del río Duwamish que es seguro para comer es el salmon
មានតែត្រីសាលម៉ុនមួយគត់ដែលមានសុវត្ថិភាពសម្រាប់បរិភោគពីស្ទឹងឌូវ៉មមីស្ស

EPA | Public Health Seattle & King County

ទិដ្ឋភាពទូទៅនៃកម្មវិធី

កម្មវិធីរបស់អង្គការការពារបរិស្ថាន (EPA) Fun to Catch, Toxic to Eat សំរាប់ស្ទឹងឌូវ៉មមីស្ស Superfund Site បានច្រឹតនូវវិធីសាស្ត្រ សហគមន៍ផ្នែកប្រឆិតក្នុងការផ្សព្វផ្សាយសុវត្ថិភាពការបរិភោគអាហារសមុទ្រ។ គោលការណ៍គឺបង្កើនសុវត្ថិភាពសកម្មភាពឲ្យសមស្របទៅនិងតម្លៃការនៃប្រពៃណីរបស់សហគមន៍ដើម្បីការពារសុខភាពរបស់សហគមន៍អ្នកសូច ឬ(ឆេសាទ) ជាពិសេសស្ត្រីមានផ្ទៃ ម្តាយណាបំបៅដោះកូន ហើយនិងកូនក្មេងតូច ជៀសផុតអំពីការទទួលទានអាហារសមុទ្រដែលមានសារជាតិគីមីពុលពីស្ទឹងឌូវ៉មមីស្ស កំឡុងពេលការសំអាតស្ទឹង។

ការមិនសមាមាត្រនៃការបំពុលឬសារជាតិគីមីពុលធ្វើឲ្យប៉ះពាល់ដល់សហគមន៍អ្នកសូចរបស់ជនអន្តោប្រវេសន៍និងជនភៀសខ្លួន។ សញ្ញាដំបូងឆ្នាតស្តីអំពីចំរាមសំរាប់សុវត្ថិភាពសុខភាពមិនមានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយដំណឹងដល់សហគមន៍អ្នកសូចដែលមិនចេះភាសាអង្គ្លេស។ អ្នកសូចទាំងឡាយមកពីតំបន់ខាងត្បូង/ ខាងលិចទីក្រុងស៊ីអាថុល ហើយនិងតំបន់យ៉ីងខោនធីភាគខាងត្បូង

ក្រសួងសុខាភិបាលសុខភាពយ៉ីងខោនធីជាអ្នកដឹកមុខរបស់កម្មវិធីជំនួសអង្គការការពារ

បរិស្ថាន។ កម្មវិធីនេះបើកដំណើរការក្នុងឆ្នាំ២០១៧ ផ្តោតទៅលើការបង្កើតស្តាប់ធ្នឹតគ្រប់ងឫត្រួតពិនិត្យសុវត្ថិភាពការទទួលទានអាហារសមុទ្ររបស់អង្គការការពារបរិស្ថានដែលជាផ្នែកនៃគម្រោងការណ៍ក្នុងការសំអាតស្ទឹងឌូវ៉មមីស្ស LDW Superfund.

Community Informs All Stages

សហគមន៍មានការជូនដំណឹងគ្រប់ដំណាក់កាលទាំងអស់



PHOTO CREDITS: Public Health

កម្មវិធីនេះផ្តុះបញ្ជាំងអំពីគោលការយុត្តិធម៌បរិស្ថាន :

- បង្កើនសមត្ថភាព - អប់រំបណ្តុះបណ្តាលសមាជិកសហគមន៍ឲ្យទៅជាអ្នកតស៊ូមតិ សហគមន៍សុខភាព (CHAs) ហើយនិងជួយផ្តល់ជំនួយថវិការសំរាប់សហគមន៍។
- ការចូលរួមដោយមានអត្ថន័យ -ចូលរួមបង្កើតឧបករណ៍ផ្សព្វផ្សាយនិងផ្តល់គំនិតយោបល់ក្នុងការបង្កើតគម្រោង។
- ការពង្រឹងនិងផ្តល់អំណាច - គាំទ្ររូវគំនិតនិងយោបល់ឬសំលេង ហើយនិងការសំរេចចិត្តរបស់សហគមន៍

ដោយសារមានជំងឺរាតត្បាតពាសពេញពិភពលោកនៅក្នុងឆ្នាំ ២០២០ គ្រប់ផ្នែកទាំងអស់នៃកម្មវិធីត្រូវបានផ្លាស់ប្តូរនិងកែសម្រួលដើម្បីគោរពតាមគោលការណ៍ណែនាំអោយរក្សាគម្លាតឃ្លាតឆ្ងាយពីគ្នាក្នុងសង្គមនិងការពារសុខភាពនិងសុវត្ថិភាពរបស់បុគ្គលិកនិងក្រុមការងារ CHAs ។ ក្រុមការងារ CHA បានបន្តរធ្វើឱ្យសកម្មក្នុងកម្មវិធីនិងជួបគ្នាជាក្រុមពីចំងាយតាមរយៈអេឡិចត្រូនិចដើម្បីធ្វើការផ្សព្វផ្សាយនិងចូលរួមអង្គប្រជុំតាមរយៈវេទិការអនឡាញ។ ដោយរួបរួមគ្នា ក្រសួងសុខភាពសាធារណៈនិង ក្រុមការងារ CHA បានរៀបចំនិងសម្របសម្រួលអង្គប្រជុំគណៈកម្មាធិការដឹកនាំសហគមន៍ (CSC) ដោយបានចូលរួមធ្វើបទបង្ហាញនៅអង្គប្រជុំជាមួយអ្នករួមចំណែកសម្ពាតរបស់ EPA និងបានរៀបចំផែនការអនុវត្តនូវយុទ្ធសាស្ត្រក្លឹបឆេសាទនិងសិក្ខាសាលាអប់រំម្តាយ។ CHA ក៏បានធ្វើបទសម្ពាសន៍តាមវិទ្យុផ្សាយផ្ទាល់ បង្ហាញពីរបៀបធ្វើម្ហូបត្រីសាលម៉ុនហើយនិងនៅពេលគេបើកអោយឆេសាទត្រីវិញនៅក្នុងរដូវក្តៅឆ្នាំ ២០២០ ក្រុមការ ងារ CHA ទៅកំពង់ផែដើម្បីជួបអ្នកឆេសាទ ផ្តល់ពត៌មានអោយពួកគេ ដោយពាក់ម៉ាស់និងរក្សាគម្លាតឃ្លាតឆ្ងាយពីពួកគេ។ ខណៈដែលក្រុមការងារ CHA សហការគ្នាជាមួយក្រសួងសុខភាពសាធារណៈដើម្បីស្វែងរកជម្រើសនិងផ្នែកប្រឆិតរកជំណោះស្រាយឧបសគ្គក្នុងការផ្លាស់ប្តូរទៅវេទិកាតាមរយៈអនឡាញ វាគឺជាការលំបាកក្នុងការស្វែងរកវិធីផ្សេងទៀងមកជំនួសសម្រាប់លើកទឹកចិត្តនិងភាពស្និទ្ធស្នាលនិងគ្នាតាមរបៀបធ្វើការផ្សព្វផ្សាយដោយជួបមុខផ្ទាល់។.

"វាមិនមែនជារឿងអាថ៍កំបាំងទេដែលវាជាការលំបាកក្នុង ឆ្នាំ នេះ ដោយសារជំងឺកូវីត១៩ យើងមិនអាចជួប គ្នា ផ្ទាល់ មុខទាល់តែសោះ"

—Grupo Asesor Latino (GAL) CHA

២ ការរចនានិងបង្កើតឧបករណ៍តម្រូវតាមការ ផ្តល់យោបល់ពីសហគមន៍

ក្រសួងសុខភាពសាធារណៈបានធ្វើការជាមួយក្រុមការងារ CHAs រៀបចំផែនការនិងឧបករណ៍នានាដើម្បីបង្កើតក្លឹបឆេសាទនៅស្ទឹងឌូវ៉មមីសនិងយុទ្ធសាស្ត្រាប់ផ្ទាក់អប់រំម្តាយ។ យុទ្ធសាស្ត្រទាំងនេះជួយលើកតម្កើងការឆេសាទអោយបានល្អប្រសើរនៅតាមទីតាំងផ្សេងៗ ដែលឆេសាទតែត្រីសាម៉ុនតែប៉ុណ្ណោះនៅក្នុងស្ទឹងឌូវ៉មមីស ជ្រើសរើសតែអាហារសមុទ្រណាល្អៗមកធ្វើជាម្ហូបនិងបរិភោគសម្រាប់សុខភាព។ ក្រុមការងារនីមួយៗត្រូវបានរៀបចំផែនការគម្រោងរចនាសម្ព័ន្ធដើម្បីអោយបានសម្រេចតាមគោល បំណងនៃយុទ្ធសាស្ត្រនីមួយៗ រួមទាំងការវាយតំលៃការអប់រំ និងឧបករណ៍ប្រើប្រាស់សម្រាប់ផ្សព្វផ្សាយ។

ក្រុមការងារយុទ្ធសាស្ត្រក្លឹបឆេសាទត្រីស្ទឹងឌូវ៉មមិស

ក្រុមការងាររបស់អ្នកឆេសាទត្រីបានរចនាអារយ៉ីត ម្ហូបប្រអប់សម្រាប់ស្ងួចត្រីនិងពាតសម្រាប់ការប្រគួតឆេសាទត្រីសាលម៉ុនក្នុងគោលបំណងផ្សព្វផ្សាយសារពត៌មានកម្មវិធី។ សមាជិកក្លឹបនីមួយៗក៏នឹងបំពេញកិច្ចសន្យាផងដែរនូវឧទាហរណ៍ ដូចជា "ខ្ញុំប្តេជ្ញាឆេសាទតែត្រីសាលម៉ុននៅក្នុងស្ទឹងឌូវ៉មមីស។"

DUWAMISH FISHING CLUB

ក្រុមការងារយុទ្ធសាស្ត្ររបស់ម្តាយនិងអ្នកថែទាំ

ក្រុមការងារ CHAs ធ្វើការនៅក្នុងក្រុមការងារម្តាយបានបង្កើតសិក្ខាសាលាចំនួន ៣ វគ្គ ដើម្បីបង្រៀនអ្នកចូលរួមអំពីប្រធានបទផ្សេងៗពីជាតិកខ្វក់។ ពួកគេបានបង្កើតកម្រងសំណួរ ថែមទៀតទៅក្នុងរូបមន្តកាតធ្វើម្ហូបនិងឧបករណ៍ផ្សេងទៀតដើម្បីលើកតម្កើងការបរិភោគអាហារសមុទ្រល្អៗសម្រាប់សុខភាព។

CHA ហើយនិងកូនរបស់គាត់ ប្រកបដោយការអប់រំនិងឧបករណ៍ផ្សព្វផ្សាយសម្រាប់យកមកប្រើក្នុងសិក្ខាសាលារបស់ម្តាយ។

ចំនួន ៤២៥

ម៉ោង អ្នកតស៊ូមតិសហគមន៍សុខភាពចំណាយក្នុងការសហការគ្នាជាមួយនិងក្រសួងសុខាភិបាលសុខភាព ហើយនិងគូភាគីដ៏ទៃទៀត ដើម្បីបង្កើតឧបករណ៍ផ្សព្វផ្សាយ។

ក្រុមការងារ CHAs រៀតណាម បានចាប់ផ្តើមដំបូងស្វែងរកសមាជិកមកចូលរួមក្នុងក្លឹបឆេសាទក្នុងកំឡុងពេលធ្វើការផ្សព្វផ្សាយនៅតាមផែនិងទីកន្លែងឆេសាទ។

ការនិទានរឿងតាមបែបឌីជីថល

ក្រុមការងារ CHAs ជាច្រើនតាក់ធ្វើការនៅក្នុងក្រុមការងាររបស់ម្តាយ បានបង្កើតរឿងនិទានឌីជីថលផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីប្រើជាផ្នែកមួយនៃកម្មវិធីសិក្សាក្នុងសិក្ខាសាលា។

ដំណើរមឿងរបស់ Roxana

ដំណើរមឿងរបស់ Mai

ដំណើរមឿងរបស់ Luz Maria

សៀវភៅគំនូរពណ៌ារបស់ក្មេងដែលរចនាដោយវិចិត្រករ Erin Shigaki.

ក្រុមសម្របសម្រួលខាងផ្តល់មតិ GAL CHA នឹងប្រមូលយកការផ្តល់មតិពីសហគមន៍នៅលើការរចនាផ្ទាត់ពណ៌សៀវភៅ។

បង្កើនសមត្ថភាពសហគមន៍

៤៨២

ម៉ោងដែលអ្នកតស៊ូមតិសហគមន៍សុខភាពចំណាយលើការកសាងក្រុមនិងហ្វឹកហាត់ជាមួយនឹងមេក្រុមព្រមទាំងបុគ្គលិកក្រសួងសុខាភិបាលសុខភាព

ក្រសួងសុខាភិបាលសុខភាពបន្តរក្សាផ្តល់នូវការហ្វឹកហាត់នឹងផ្តល់ជំនួយផ្នែកខាងបច្ចេកទេសដល់ក្រុមអ្នកតស៊ូមតិសហគមន៍សុខភាពនិងភាគីសហការអង្គការតាមក្តីត្រូវការ។

"ខ្ញុំបានឈប់ភ័យខ្លាចអំពីបច្ចេកវិទ្យា វាពិតជាមានការលំបាកពីដើមដំបូង...ប៉ុន្តែឥឡូវនេះខ្ញុំមានអារម្មណ៍ជឿជាក់ថាខ្ញុំចេះចំណេះនេះហើយខ្ញុំកំពុងបង្ហាត់បង្រៀនអ្នកដទៃទៀតពីរបៀបទទួលជោគជ័យក្នុងការប្រើប្រាស់អំពីបច្ចេកវិទ្យា"

-GAL CHA

ការងារ CSC តាមអនឡាញលើកដំបូង

"ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានរៀនចេះកាន់តែពេញនិយមពីព្រោះខ្ញុំមានពេលវេលាសិក្សា អាន ពិនិត្យមើលរាល់ព័ត៌មានទាំងអស់ដែលពួកគេបានផ្តល់អោយយើងឡើងវិញ។ ខ្ញុំមានអារម្មណ៍ជឿជាក់ជាងមុននៅពេលខ្ញុំទៅនិយាយជាមួយនរណាម្នាក់ពីព្រោះខ្ញុំមានពេលច្រើនពិនិត្យមើលព័ត៌មានឡើងវិញ។"

—GAL CHA

ការរកឃើញអំពីការវាយតម្លៃនៃ:

ចំណេះដឹង ជំនាញនិងភាពជឿជាក់របស់ក្រុមការងារ CHA បានកើនឡើងពីព្រោះពួកគេមានពេលវេលាច្រើនសិក្សាសម្ភារៈដែលទាក់ទងនឹងកម្មវិធីនិងសាបមបសម្រួលទៅនឹងស្ថានភាពជំងឺកូវីដ១៩ ហើយនិងបានអភិវឌ្ឍជំនាញកុំពូទ័រនិងទំនាក់ទំនង។

កម្មវិធីបណ្តុះបណ្តាល 2.0



ការសង្កេតមើលនិងការទទួលមតិយោបល់ពីមេក្រុមការងារ CHA តាំងអោយក្រសួងសុខភាពសាធារណៈបញ្ចប់វគ្គទី ២ នៃសៀវភៅណែនាំស្តីពីកម្មវិធីបណ្តុះបណ្តាល។

ក្រុម CHA ខ្មែរ បានប្រើប្រាស់កម្មវិធីបណ្តុះបណ្តាល វគ្គ 2.0 មកបង្ហាត់បង្រៀនសមាជិក CHA ថ្មីចំនួន ៤ នាក់ បានដោយជោគជ័យ បញ្ចូលទៅក្នុងក្រុមរបស់ពួកគេ។

បង្កើនការយល់ដឹងដល់សហគមន៍

"យើងបានសម្រួលខ្លួនទៅនិងស្ថានភាពថ្មីនេះ។ យើងមិនបានធ្វើការផ្សព្វផ្សាយជាមួយសហគមន៍ប៉ុន្តែយើងបានធ្វើការផ្សព្វផ្សាយរៀងៗខ្លួន។ថ្មីៗនេះ យើងបានចាប់ផ្តើមការផ្សព្វផ្សាយតាមរយៈវិទ្យុ ហើយខ្ញុំមានអារម្មណ៍ថាក្នុងនាមជាក្រុម បានជោគជ័យសម្រាប់យើង។"

-GAL CHA

"មនុស្សភាគច្រើនមិនដឹងពីរបៀបប្រើស៊ីមទេ ដូចនេះយើងត្រូវប្រើទូរស័ព្ទ... ហើយចំនួនពត៌មានចែករំលែកតាមទូរស័ព្ទមានកំណត់។"

-Vietnamese CHA

ក្រុមការងារ CHAs ខ្មែរ ធ្វើការផ្សព្វផ្សាយនៅតាមផែក្នុងតំបន់។

ក្រុមការងារ CHA ខ្មែរ ផ្សព្វផ្សាយអោយសហគមន៍ដឹងពួតាមរយៈការដកក្តារនៅខាងក្រោយផ្ទះ។



ក្រុមការងារ GAL CHA បានធ្វើព្រឹត្តការណ៍ផ្សព្វ ផ្សាយផ្ទាល់តាមរយៈវិទ្យុ លើបណ្តាញហ្សេសប៊ុក មានអ្នកទស្សនាជិត ៣០០ នាក់។

សកម្មភាពផ្សព្វផ្សាយចំនួន៣៨ដង

សកម្មភាពផ្សព្វផ្សាយចំនួន ៣៨ ដង នៅតាមផែនេសាទត្រីធ្វើការជួបជុំគ្នាតាមអនឡាញ ជួបគ្នាតាមរយៈទូរស័ព្ទមួយទល់និងមួយ ហើយនិងជួបគ្នាជាក្រុមតូចៗនៅខាងក្រោយផ្ទះ

៤១៩ នាក់ត្រូវបានទទួលការផ្សព្វផ្សាយ

ចំនួន ២០៩ ម៉ោងអ្នកតស៊ូមតិសហគមន៍សុខភាពបានចំណាយជាកគម្រោងការណ៍និងធ្វើការផ្សព្វផ្សាយ

ជំនួយនិងគាំទ្រសម្លេងរបស់សហគមន៍

ក្រុមការងារ CHA នីមួយៗ បានដាក់វេនគ្នា ដឹកនាំអង្គប្រជុំ CSC ដោយមានការគាំទ្រនិងសម្របសម្រួលពីក្រសួងសុខភាពសាធារណៈនិងក្រុមចម្បាង។ CHA បានបន្តរធ្វើបទបង្ហាញនិងចូលរួមអង្គប្រជុំតាមអនឡាញនៅក្នុងតំបន់និងទូទាំងប្រទេស ចូលរួមក្នុងអង្គប្រជុំជាមួយអ្នកពាក់ព័ន្ធសម្ពាគស្ទីងឌូរ៉ាមមីស និងការបណ្តុះបណ្តាលដែលវៀបចំឡើងដោយ EPA ដើម្បីផ្តល់ការយល់ដឹងអោយបានកាន់តែច្បាស់ដល់សហគមន៍អំពីការសម្ពាគ។

ក្រសួងសុខាភិបាលសុខភាពបានប៉ាន់តម្លៃនៃការចូលរួមរបស់គណកម្មការដឹកនាំសហគមន៍សុខភាព បានចម្លើយដូចជា:

សមាជិក CSC មានអារម្មណ៍ថា មានការគាំទ្រលើយត្រូវបានគេគោរពនៅពេលឡើងនិយាយក្នុងអង្គប្រជុំ។ សមាជិកក៏មានអារម្មណ៍ផ្ទាល់ផ្ទៃរថា មានគេស្តាប់និងអោយតម្លៃដល់ពួកគេ។

ចំនួន ៥៧៧ ម៉ោង ដែលអ្នកតស៊ូមតិសហគមន៍សុខភាពចំណាយ ក្នុងការចូលរួមផ្តល់នូវគំនិតនិងការសម្រេចចិត្តក្នុងកម្មវិធីដល់អង្គការផ្សេងៗ។

មានការប្រជុំ ៤ ដងរបស់ គណកម្មការដឹកនាំសហគមន៍

"សូមកោតសរសើរដ៏ខ្ពង់ខ្ពស់លើបទបង្ហាញរបស់ក្រុមការងារ CHA! ការសរសើរយ៉ាងរីករាយ...ការសប្បាយរីករាយ មានពន្លឺ មានភាពវិជ្ជមាន និងមានអារម្មណ៍ថា "យើងសហការគ្នាធ្វើការបានយ៉ាងល្អ" មានភាពទូលំទូលាយនៅក្នុងមតិយោបល់របស់អ្នករាល់គ្នាអំពីកិច្ចប្រជុំទូទៅនិងជាពិសេសអំពីកម្មវិធី IC ។ សូមអរគុណ!..." *-EPA*

"យើងមិនត្រឹមតែត្រូវបានគេអោយមានវត្តមាននៅក្នុងអង្គប្រជុំប៉ុណ្ណោះទេ ប៉ុន្តែក៏ជាផ្នែកមួយនៃគណៈកម្មាធិការដឹកនាំហើយនិងបានទទួលការបណ្តុះបណ្តាលដើម្បីយល់កាន់តែច្បាស់អំពីដំណើរការនៃការសម្ពាគដែលធ្វើឱ្យយើងមានអារម្មណ៍ថា យើងមានចំណែកនិងត្រូវបានគេទទួលស្គាល់។ —CHA

"មានវត្តមាននៅក្នុងអង្គប្រជុំតំបូល ធ្វើឱ្យយើងមានឥទ្ធិពលកាន់តែច្រើនតិចមមទៀត។ វាជាកន្លែតមួយផ្សេងទៀត ... យើងមានឱកាសក្លាយជាផ្នែកមួយនៃក្រុមតូមូលហើយធ្វើការសម្រេចចិត្ត។"

—មេក្រុម



ដោយសារតែការងារដ៏អស្ចារ្យបានធ្វើនៅក្នុងកម្មវិធីនេះក្រសួងសុខភាពសាធារណៈនិង CHAs ត្រូវបានជ្រើសរើសជាពានគំរូរបស់សមាគមន៍ National Association of County & City Health (NACCHO) Model Practice award (NACCHO)។

ក្នុងឆ្នាំ ២០២០ ក្រសួងសុខាភិបាលសុខភាពបានសហការជាមួយ:

Refugee Federation Service Center

អ្នកតស៊ូមតិសុខភាពសហគមន៍ខ្មែរ ខ្មែរ CHA Khmer Community Health Advocate

GAL GRUPO ASESOR LATINO

LOWER DUWAMISH WATERWAY GROUP

Latino Community Fund WASHINGTON STATE

Port of Seattle

2020 Model Practice AWARD NACCHO

ទំនាក់ទំនងរបស់កម្មវិធី

EPA

អង្គការការពារបរិស្ថាន តំបន់ទី១០
Piper Peterson, (206) 553-4951, peterson.piper@epa.gov

ក្រសួងសុខាភិបាលសុខភាពស៊ីអាថ្ងលយើង ខោនធី
Sinang Lee, (206) 263-1192, sinang.lee@kingcounty.gov

www.kingcounty.gov/duwamish-fishing

Public Health Seattle & King County